# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៥-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៥៦ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ប្រាត់ ចំរើន** ពីអនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២៥៨១

១៥-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៥៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសុវត្ថារា តាមលំដាប់ថ្នាក់ ចំពោះមន្ត្រីរាជការ ចំនួន ៥៣ រូប ២៥៨២

១៥-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៥៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ ចំនួន ០២ រូប ២៥៨៤

១៦-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៥៩ ស្តីពី ការតែងតាំងឯកឧត្តម **ខៅ ផល្លី** ជាឧកញ៉ា ២៥៨៥

១៦-៣-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៦០ ស្តីពី ការតែងតាំងឯកឧត្តម **ម៉ាន់ ពំម៉ុន**, ឯកឧត្តម **ទូច សុផានី**,ឯកឧត្តម **អោ វឌ្ឍមុនី** និងឯកឧត្តម **ព្រំ ឡុងនី** ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ និង តម្លើងឋានៈជូនឯកឧត្តម **ហាន ឌុទ្ធិ**, ឯកឧត្តម **ហួត ហ៊ាង** ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ២៥៨៦

១៦-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៦១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ឡាង គាង** ពីទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់សាមីខ្លួន ២៥៨៧

០៦-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៦២ ស្តីពី ការតែងតាំងលោកជំទាវ **សន ម៉ារ៉ាដា** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ២៥៨៨

១៦-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៦៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះសប្បុរសជន ចំនួន ០៣ រូប ២៥៨៩

១៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៦៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ Mr.Morihata Shingo ២៥៩០

១៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៦៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះព្រះសង្ឃ និង សប្បុរសជន ចំនួន ១៦ រូប ២៥៩១

១៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៦៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៤ រូប ២៥៩៣

១៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៧០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះឯកឧត្តម ចំនួន ០៣ រូប ២៥៩៤

១៩-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៧១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះឧកញ៉ា **អ៊ុន យុទ្ធី** ២៥៩៥

២២-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៧២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ១៦ រូប ២៥៩៦

២២-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៧៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ២០ រូប ២៥៩៧

២២-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៧៦ ស្តីពី ការតែងតាំងទីប្រឹក្សា នាយក នាយករង និង ជំនួយការ ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ចំនួន ០២ រូប បន្ថែមលើមុខងារបច្ចុប្បន្ន ២៥៩៩

២២-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៧៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ មន្ត្រីរាជការស៊ីវិលនៅខេត្តស្វាយរៀង ចំនួន ០២ រូប ២៦០០

២២-៣-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៣១១/២៧៨ ស្តីពី ការដាក់មន្ត្រីរាជការឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ចំនួន ០៧ រូប ២៦០១

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២១-៣-២០១១ -អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៦៤៦ ហិកតាក្នុងដែនជម្រកសត្វព្រៃ បឹងពែរ ភូមិសាស្ត្រខេត្តព្រះវិហារ ២៦០៣

២១-៣-២០១១ -អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៩៤៦ ហិកតាក្នុងដែនជម្រកសត្វព្រៃ បឹងពែរ ភូមិសាស្ត្រខេត្តកំពង់ធំ និង ខេត្តសៀមរាប ២៦០៦

២៤-៣-២០១១ -អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ២៦០៩

២៥-៣-២០១១ -អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១០.០០០ ហិកតាស្ថិតនៅក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី ២៦២៥

២៥-៣-២០១១ -អនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពី ការទទួលស្គាល់វិទ្យាស្ថានប៉េ អេស អ៊ី ២៦២៧
១៨-៣-២០១១ -អនុក្រឹត្យលេខ ៣០៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៦៣០
១៨-៣-២០១១ -អនុក្រឹត្យលេខ ៣០៦ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ២៦៣២
១៨-៣-២០១១ -អនុក្រឹត្យលេខ ៣០៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៦៣៣
២១-៣-២០១១ -អនុក្រឹត្យលេខ ៣០៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ២៦៣៤
២១-៣-២០១១ -អនុក្រឹត្យលេខ ៣០៩ អនក្រ.តត ស្តីពី ការតែងតាំង និង ផ្ទេរភារកិច្ចមន្ត្រីរាជការ ២៦៣៦
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១០ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២៦៣៨
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៦៤០
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១២ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២៦៤២
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១៣ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២៦៤៧
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៦៤៩
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១៥ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែង នាយនគរបាលជាតិ ២៦៥១
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១៦ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ២៦៥៣
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១៧ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២៦៥៥
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១៨ អនក្រ.តត ស្តីពី ការ ជូនមេដាយសុវត្ថារា ២៦៥៦
២១-៣-២០១១ -អនុក្រឹត្យលេខ ៣១៩ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ២៦៥៧
២១-៣-២០១១ -អនុក្រឹត្យលេខ ៣២០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៦៦០
២២-៣-២០១១ -អនុក្រឹត្យលេខ ៣២១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ២៦៦១
២២-៣-២០១១ -អនុក្រឹត្យលេខ ៣២២ អនក្រ.តត ស្តីពី ការតែងតាំងប្រធានអគ្គនាយករបស់ធនាគារអភិវឌ្ឍន៍ជនបទ ២៦៦២
២២-៣-២០១១ -អនុក្រឹត្យលេខ ៣២៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ២៦៦៤

## ២_សេចក្តីសម្រេច

២៣-៣-២០១១-សេចក្តីសម្រេចលេខ ២២ សសរ ស្តីពី ការបង្កើតក្រុមការងារអន្តរក្រសួងសម្រាប់សម្របសម្រួលព័ត៌មានពីសមរភូមិ ២៦៦៦

## ៣_សារាចរណែនាំ

២២-៣-២០១១-សារាចរណែនាំលេខ ០៣ សរណន ស្តីពី ការគ្រប់គ្រងគ្រោះអាសន្ន នៅក្នុង និងក្បែរអាកាសយានដ្ឋាន នៃព្រះរាជាណាចក្រកម្ពុជា ២៦៦៨

## III‑ការងារបណ្ដាក្រសួង

### ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១២-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៣៤ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ
សហគ្រាសឯកបុគ្គល និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន
**សេនស៍ ជើនី ត្រាវ៉ែល** ២៦៧៥
១២-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៣៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីនីម៉ិច ខូ អិលធីឌី** ២៦៧៧
១២-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៣៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើណល ស៊ីឃ្យូរីធី**
**អគឃ្យូផេសិន** ២៦៧៩
១២-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៤០ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង
តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ខេមបូឌា អ៊ិនធើរណេស្ស៊ូណល អ៊ិនវេស្តមែន ឌីវេ**
**ឡុបម៉ែន គ្រុប** ២៦៨១
១២-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៤២ ពណ.ចបព ស្តីពី ការចុះបញ្ជីពាណិជ្ជកម្ម និងទទួល
ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វិហ្គីស ប៊ីហ្សូនេស សេនធ័រ**
**(ខេមបូឌា) ខូ អិលធីឌី** ២៦៨៣
១២-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៤៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេហ្គា ច័ន អ៊ិនធើរណេ**
**សិនណល (ខេមបូឌា)** ២៦៨៥
១២-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៤៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គា ហ៊ីង (ខេមបូឌា) អ៊ិន**
**វេសមេន** ២៦៨៧
១៨-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៤៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាន់អ៊ិល ខនសាល់ធីង គ្រុប** ២៦៨៩
១៩-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាមបាច ហាន ឌារធីឌើរ** ២៦៩១
១២-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពន្លឺតារា ខនស្ត្រាក់សិន** ២៦៩៣
១៩-៥-២០១០ -លិខិតបញ្ជាក់លេខ ២២៥០ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ
លក្ខន្តិកៈរបស់ក្រុមហ៊ុន **ហ្វូលីង ភ្នំពូធ័រ អឹមប្រយឌើរី** ២៦៩៥

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៥៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ប្រាក់ ចំរើន** ពីអនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៣.២៦១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១១

លេខៈ ២៤៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

**យុន ជិនភេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៥៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការចំនួន ៥៣រូប ដែលមានស្នាដៃល្អក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល
បានចូលរួមអភិវឌ្ឍន៍នៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

នូវ

**ក- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

១- ឯកឧត្តម តិត សាលី
២- ឯកឧត្តម ចេង ញ៉ាន់
៣- ឯ.ឧបណ្ឌិត យិត មុណ្ណា
៤- ឯ.ឧបណ្ឌិត ភី សីដា
៥- បណ្ឌិត សុខ ឆួច
៦- ឯកឧត្តម សេង គីមសាន
៧- ឯកឧត្តម ជា គីមហាន
៨- លោក សៅ ចន្ថនា
៩- លោក ខ៉ាន ណារី

**ខ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ ធិបឌិន្ទ :**

១- ឯកឧត្តម សេង វីនោរ
២- លោក អ៊ុយ សោភ័គ
៣- លោក អ៊ុន សុផាលី
៤- លោក លឹម ល្មៀងខ្លួន
៥- លោក សេង ដារ៉ាក្រពុំ
៦- លោក គិត មិនារិទ្ធ
៧- លោក សេង ប៊ុនឈឿន
៨- លោក សុង សារឿន
៩- លោក មួយ ថាន់
១០- លោក អ៊ុន សុផល
១១- លោក កែវ ពៅ

**គ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ សេនា :**

១- លោក ឯម ម៉ារឌី
២- លោក គង់ ឋាន្នី
៣- លោក ឆាយ ចណ្ណៈ
៤- លោក ឱក្យ សារុ
៥- លោក នៅ ឃែល
៦- លោក តួច ដាំម៉ូរី
៧- លោក ញឹម សុខា
៨- លោក សោភ័ណ និរិនិទ្ធ

**ឃ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ អស្សឫទ្ធិ :**

| | |
|---|---|
| ១- លោក ហម គឹមគង់ | ២- លោក ប៊ុត តារារិទ្ធ |
| ៣- លោក ប្រាត់ សុទ្ធ | ៤- លោក អ៊ុំ សារ៉េត |
| ៥- លោក ឆាយ ប៊ូ | ៦- លោក នូ ឫទ្ធី |
| ៧- លោក ម៉ត់ ប៉ូលីប៉ាត់ | ៨- លោក គ្រឹង សំអាត |
| ៩- លោក គង់ ណារិទ្ធ | ១០- លោក ម៉ឹង ឈុនហេង |
| ១១- លោក ជា សុខឃីម | ១២- លោក ណារិន ពិសិដ្ឋ |
| ១៣- លោក អឿ ម៉េងចុង | ១៤- លោក អ៊ុត ហៀង |
| ១៥- លោក គី សាថិន | ១៦- លោក ឆេង ផល្លា |
| ១៧- លោក ស្វាយ ឌិត | ១៨- លោក ប៉ាត់ គន |
| ១៩- លោក ហួន ហេងសិរិយា | ២០- លោក នៃ ឈាន |
| ២១- លោក យន់ តាណាដា | ២២- លោក ហ៊ង ឡៃរ៉ាប៊ូ |
| ២៣- លោក អ៊ុំ ផុន | ២៤- លោក លុយ សាំ |
| ២៥- លោក យូង សីថលី | |

៣៩ល. ១១០៣. ២៦២

**បានប្រថាប់ព្រះរាជលញ្ចករហើយ** **នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១១*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

លេខ : ០០៣៧/២២ រ.ចច

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០២២

សម្តេចចៅហ្វាវាំងវរវៀងជ័យ អធិបតីស្រីឧត្តម **គង់ សំអុល**

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៥៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្រ័យ ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការ ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា ក្នុងវិស័យ-ព្រះពុទ្ធសាសនា និងសង្គមកិច្ច នៅក្នុងខេត្តព្រៃវែង

**នូវ**

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

ឯកឧត្តម **ចែម ទុឡ្ហិការ**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

លោក **ជា សួរ**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
**នរោត្តម សីហមុនី**

៣រល. ១១០៣.២៦៣

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១១

លេខ: ២៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

ឯកឧត្តម ចៅ ផល្លី

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១១០៣.២៦៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

លេខ: ៧៥១ ច.ល
...ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន មិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៦០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ម៉ាន់ រ៉ាម៉ុន**, ឯកឧត្តម **ឌុច សុផានី**, ឯកឧត្តម **អោ វឌ្ឍមុនី** និងឯកឧត្តម **ស្រ៊ី ស៊ុខនី** ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ**

**មាត្រា ២:** តម្លើងឋានៈជូនឯកឧត្តម **ហាន់ វុទ្ធី** , ឯកឧត្តម **ហួត ម៉ាច** ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៣. ២៦៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

លេខ: ៧៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ឡាច ភាច** ពីទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសំណើរបស់សាមីខ្លួន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៣.២៥៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

លេខ: ៧៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ៣ ឆ្នាំ២០១១
អគ្គលេខាធិការរដ្ឋាភិបាល

**យុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៦២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/0៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងលោកជំទាវ ***សន ម៉ារ៉ាជា*** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៣.២៦៧

*ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១*

លេខ: ៤៣៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ មីនា ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៦៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

**ចំពោះ**

សប្បុរសជន ចំនួន០៣ រូប ដែលបានឧបត្ថម្ភ ថវិកា និង សម្ភារៈ
ជួយកសាងនិងអភិវឌ្ឍន៍ កងការពារព្រំដែនគោកលេខ ៥០២ នៃ យោធភូមិភាគទី ៥

**នូវ**

**គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១ លោក **ប៉ែន រដ្ឋា**
២ លោក **យ៉ាង វណ្ណៈ**
៣ លោកជំទាវ **ឡៃ គីមហុង ម៉ុន សេង**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៣.២៦៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

លេខៈ ៧៤៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនភេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

ចំពោះ

Mr. Morihata Shingo

ដែលមានស្នាដៃធំធេង លើគម្រោងកែលំអកំណាត់ផ្លូវជាតិលេខ១ គម្រោងសាងសង់ស្ពានអ្នកលឿង
គម្រោងពង្រឹងគុណភាពសំណង់ និងជំនួយការច្បាប់គោលនយោបាយលើវិស័យសាធារណការ និងដឹកជញ្ជូន

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រ៧. ១១០៣. ២៧២

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១១

លេខៈ ២៦១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ០៣ ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ឌិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៦៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

## ចំពោះ

ព្រះសង្ឃ និងសប្បុរសជន ចំនួន១៦រូប មានស្នាដៃល្អ និងគុណបំណាច់ខ្ពស់
ក្នុងការកសាង និងអភិវឌ្ឍន៍លើវិស័យព្រះពុទ្ធសាសនា នៅក្នុងវត្តឧត្តមព្រឹក្សា
នៅឃុំព្រៃកក្រាញ់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

## នូវ

### ក.គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១- ព្រះគ្រូសន្តោ សត្តេនោ **នៅ សុខា**

### ខ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- លោកជំទាវ **ជា ខេង ស៊ុយ សែម**
២- លោកជំទាវ **ឡូ គីម**
៣- លោក **កែ សាខន**
៤- លោកជំទាវ **ប៊ុក ប៊ុនរិទ្ធ ពេជ សោភ័ណ**
៥- លោកជំទាវ **ហួង សួន ស៊ីគង់ ធ្វីច**
៦- លោកជំទាវ **ហ្វូ ឆេងសៀង ចិញហ្វូ**
៧- លោក MIKKEL WAKERFIELD
៨- លោកជំទាវ **លឹម ឆេង តាន់ គីមថិន**
៩- លោក TOM KIMSON
១០-លោក CHAN HUYLUONG

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**គ.គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- លោកជំទាវឧកញ៉ា **ជឹង សុគន្ធាទី**

**ឃ.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- កញ្ញា **ឡាច សុខហ៊ុយ**

២- លោក **ពេជ អតិរៈ**

**ង.គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១- លោកជំទាវ **ឈូ សុខឡេង**

២- លោកស្រី **ឆឹង ចិន្តា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៣.៤៧៣

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១

លេខ ៤៦៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០១១
**មន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីប្រចាំការរាជរដ្ឋាភិបាល**

**យុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៦៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចខាងក្រោមៈ

**ក-ថ្នាក់ឧត្តមសេនីយ៍ទោ**

១- លោកស្រីឧត្តមសេនីយ៍ត្រី **សុខ សម្បត្តិ** អត្តលេខ ០២២២០

២- លោកស្រីឧត្តមសេនីយ៍ត្រី **យក់ សុខា** អត្តលេខ ០២២៦០ ។

**ខ-ថ្នាក់ឧត្តមសេនីយ៍ត្រី**

១- លោកស្រីវរសេនីយ៍ឯក **អ៊ឹម ឌូ** អត្តលេខ ០២២០១

២- លោកស្រីវរសេនីយ៍ឯក **ខ៊ែត ម៉ាលី** អត្តលេខ ០២១៦០ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុក អនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ២៥៩ ច.ល
**ចម្លងចែកជូន**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុន ចិនកេន**

៣រល. ១១០៣.២៧៤

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-ឯកឧត្តម ពេជ សោភ័ន
២-ឯកឧត្តម អូស្មាន ហាស្សាន់
៣-ឯកឧត្តម ភាន់ ម៉ែន

នូវ

## គ្រឿងឥស្សរិយយស ជាតូបការ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.១១០៣.២៧៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១១

លេខ: ៥៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

## គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

ចំពោះ

## ឧកញ៉ា អ៊ុន យុទ្ធី

សប្បុរសជនបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងព្រះវិហារនិងសមិទ្ធផលនានា
នៅវត្តទួលសុភី ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.១១០៣.២៧៦

ធ្វើនៅព្រះបរមរាជវាំង .ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១១

លេខ: ២៧០ ច.ល
ជូនចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជិនភេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៧២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ១៩ រូប ដែលមានគុណបំណាច់ក្នុងការបម្រើជាតិ មាតុភូមិ

**នូវ**

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ឯកឧត្តម **ប៉ែន គូសល្យ** ២-លោកជំទាវ **ហៅ ច័ន្ទសេរីវេធី**

៣- ឯកឧត្តម **អ៊ុត ភារៈ** ៤-ឯកឧត្តម **នាត់ ឌីឡែន**

ខ-គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-ឧកញ៉ា **អ៊ុង លីហេង** ២-លោកឧត្តមសេនីយ៍ត្រី **ជា ថាវរៈជាតិ**

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១-ព្រះគ្រូបិតកយសោ **សោ ប៊ុនឡេង** ២-លោកជំទាវ **សំ គេតមុនី**

៣-ឯកឧត្តម **សូ សូចំនួ** ៤-លោកជំទាវ **ឈាង នរីឧត្តី**

៥-លោក **ណង ថា** ៦-លោកវរសេនីយ៍ទោ **ឈឹម និត្យរិទ្ធី**

ឃ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១-ឯកឧត្តមឧកញ៉ា **លឹម ឆខាយ** ២-លោក **អ៊ូ រតនា**

៣-លោក **លី យូគៀត** ៤-លោកវរសេនីយ៍ទោ **គួ គីមឃុន**

ង-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១-លោក **ជា សានិត** ២-លោក **ផាត់ ចន្ទ្រ**

៣-លោក **គង់ វីដា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.១១០៣.២៧៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១

លេខ ៤៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល
...ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

សប្បុរសជន ចំនួន ២០ រូប បានបំពេញការងារ និងចូលរួមកសាង
អភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោក ចៀក វ៉ាន់ធី
២- លោក ចាន់ សុភា
៣- លោក សារិន សុវណ្ណ
៤- លោក លី ស៊ីហ៊ីង
៥- លោក ចាន់ រិទ្ធី
៦- លោក គង់ វណ្ណរដ្ឋ

ខ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម ទេព ចិត្រា

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- លោក ម៉េង ងួនលីម
២- លោក លី សេងឃុង

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- លោក សូ ច័ន្ទណារី
២- លោក កែវ ប៊ុនរ័ត្ន
៣- លោក មិន សុផេត

ង- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

១- លោក ជា ទ្រី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោក ស៊ន វាត    ៣- លោក តែម បូរីតា

២- លោក សេង ចំរើន    ៤- លោក ទឹម ចាន់ណារិទ្ធ

ឆ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- លោក វង្ស ផល្លា    ៣- លោក ឡេង ឌីម៉ង់

២- លោក ហួល វិសិដ្ឋ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរយ. ១១០៣.២៧៩

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១១

លេខ: ២៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៧៦

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងទីប្រឹក្សា នាយក នាយករង និងជំនួយការ ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម **ជូ ទិជិត្ត** ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យ មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម **កែន សម្បត្តិ** ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៣- ឯកឧត្តម **ហោ ច័ន្ទឆាន្នី** ជាជំនួយការ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៣. ២៨១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១

**លេខ: ២៦៨ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មីនា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**យុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៧៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការស៊ីវិល នៅខេត្តស្វាយរៀង ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបំរើ
ជាតិមាតុភូមិ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

**នូវ**

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១-លោក **អ៊ុយ ថន**

២-លោក **ម៉ៅ ទីរៈ**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.១១០៣.២៩២

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១

លេខៈ ២៧២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មីនា ឆ្នាំ២០១១

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៣១១/២៧៩

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** ត្រូវបានដាក់មន្ត្រីរាជការឋានន្តរសក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួងព័ត៌មាន ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈដោយរក្សាមុខតំណែងនយោបាយដដែល

របស់គណៈកម្មការសម្រេចជាថ្មីពីរាជរដ្ឋាភិបាល ដូចមាននាមខាងក្រោម៖

| ល.រ | គោត្តនាម និងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង | ឋានន្តរសក្តិនិងថ្នាក់ | ថ្ងៃខែឆ្នាំចូលនិវត្តន៍ |
|---|---|---|---|---|---|---|
| **ក្រសួងព័ត៌មាន** | | | | | | |
| ១ | ខៀវ កាញារីទ្ធ | ប | ១៣-០៩-១៩៥១ | រដ្ឋមន្ត្រី | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០១-១០-២០១១ |
| **ក្រសួងបរិស្ថាន** | | | | | | |
| ១ | ខៀវ មុត | ប | ៣០-០៨-១៩៥១ | រដ្ឋលេខាធិការ | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០១-០៩-២០១១ |
| **ក្រសួងអភិវឌ្ឍន៍ជនបទ** | | | | | | |
| ១ | ស៊ឹម សុន | ប | ០៥-០១-១៩៥១ | រដ្ឋលេខាធិការ | ឧត្តមមន្ត្រី ថ្នាក់លេខ ១ | ០១-០២-២០១១ |
| **រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** | | | | | | |
| ១ | ម៉ិន នី | ប | ១២-០៩-១៩៥១ | អនុរដ្ឋលេខាធិការ | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០១-១០-២០១១ |

**មាត្រា ២ :** ត្រូវបានដាក់មន្ត្រីរាជការឋានន្តរសក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាមនិងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង | ឋានន្តរសក្តិនិងថ្នាក់ | ថ្ងៃខែឆ្នាំចូលនិវត្តន៍ |
|---|---|---|---|---|---|---|
| **ក្រសួងព័ត៌មាន** | | | | | | |
| ១ | ហ៊ឹម សុខ | ប | ១៨-១២-១៩៥១ | អគ្គនាយករង | ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | ០១-០១-២០១២ |
| ២ | សេង សារុន | ប | ០៩-០២-១៩៥១ | អគ្គនាយករង | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ០១-០៣-២០១១ |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | | |
| ១ | ម៉ក់ គឹមហុង | ប | ១០-១២-១៩៥១ | ប្រធានអគ្គ.ចំការកៅស៊ូ | ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | ០១-០១-២០១២ |

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.០៣១១/២៤៣

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១

លេខ: ២៧៤ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១
ទីស្តីការគណៈរដ្ឋមន្ត្រីទីស្តីការរដ្ឋាភិបាល

ឃុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៧ . អនក្រ . បក

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៦៨៦ហិកតា ក្នុងដែនជម្រក សត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តព្រះវិហារ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង ប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ **១.៦៤៦( មួយពាន់ប្រាំមួយរយសែសិបប្រាំមួយ)** ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតក្នុងភូមិសាស្ត្រ ខេត្តព្រះវិហារ ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៥៥ សជណ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទីដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន ឬធី ក្រានីត (ខេមបូឌា) ខូ អិលធីឌី

RETHY GRANITE ( CAMBODIA ) CO., LTD ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តព្រះវិហារ លើផ្ទៃដី ១៦៤៦ ហិកតា ក្នុងទីតាំងរួមទំហំ ១៩០៣ ហិកតា



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៣ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១.៩៨៦ហិកតា ក្នុងដែនជម្រក សត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តកំពង់ធំ និង ខេត្តសៀមរាប**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- យោងតាមសំណើរបស់ក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ**១.៩៤៦(មួយពាន់ប្រាំមួយរយសែសិបប្រាំមួយ)**ហិកតា ក្នុងដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតក្នុងភូមិសាស្ត្រ ខេត្តកំពង់ធំ និងខេត្តសៀមរាប ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ៩៥ សជណ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១១ របស់ទីស្តីការ គណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពី ថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

## ផែនទីដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម របស់ក្រុមហ៊ុន ស៊ី អ ស៊ី ខេ ២ C.R.C.K.2 APHIVATH CAOUTCHOUC CO., LTD
### ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ភូមិសាស្ត្រខេត្តសៀមរាប និងខេត្តកំពង់ធំ លើផ្ទៃដី ១៩៤៦ ហិកតា ក្នុងផ្ទៃដីទំហំ ២២០០ ហិកតា




**សញ្ញាសម្គាល់**

- ទីតាំងដីសំរាប់ធ្វើការដាំដុះទំហំ ១៩៤៦ ហិកតា
- ទីតាំងដីជាចំណី អូរ បឹង ត្រពាំង ទំហំ ២៥៤ ហិកតា
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង អូរ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃបឹងពែរ

| ID | N | X | Y |
|---|---|---|---|
| 1 | A | 455504 | 1464368 |
| 2 | B | 455434 | 1461430 |
| 3 | C | 447984 | 1461417 |
| 4 | D | 447936 | 1464316 |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១១
រដ្ឋលេខាធិការ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០១១
រដ្ឋលេខាធិការ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៥៤ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់
## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ការរៀបចំបណ្តាអង្គភាព នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងកំណត់បេសកកម្មរបស់ក្រសួងនិងមុខការនៃបណ្តាអគ្គនាយកដ្ឋាន និងនាយកដ្ឋាននានា។

## ជំពូកទី ២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្ម

ឲ្យដឹកនាំនិងគ្រប់គ្រងវិស័យសង្គមកិច្ច វិស័យអតីតយុទ្ធជន និងវិស័យយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានមុខងារនិងភារកិច្ច ដូចតទៅ ៖

ក-វិស័យសង្គមកិច្ច

-រៀបចំគោលនយោបាយ និងដឹកនាំ គ្រប់គ្រងរាល់សេវាសង្គមកិច្ចរបស់រដ្ឋ ដើម្បីជួយដល់ប្រភេទជនងាយរងគ្រោះនិងជនក្រីក្រ ជាអាទិ៍ ជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រា កុមារតាមចិញ្ចើមថ្នល់ ស្រីពេស្យា ជនដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងមានមេរោគឆ្លងកាចសាហាវ ជនក្រីក្រជួបការលំបាកជាងគេក្នុងសង្គម

-រៀបចំអនុវត្តគោលនយោបាយស្តីពីគ្រួសារ ជនចាស់ជរា

-រៀបចំលិខិតបទដ្ឋាននិងគ្រប់គ្រងការងារសុំកូនទៅចិញ្ចឹមនៅក្នុងនិងក្រៅប្រទេស

-រៀបចំសេវាសង្គមកិច្ច ដើម្បីថែរក្សា ការពារ និងអប់រំ កុមារកំព្រា កុមាររងគ្រោះដោយអំពើជួញដូរ ដោយជំងឺអេដស៍ កុមារពិការ និងចិញ្ចឹមបីបាច់ថែរក្សាទារកដែលត្រូវគេបោះបង់ចោល

-រៀបចំគោលការណ៍គាំពារជនពិការ អនុវត្តការងារស្តារលទ្ធភាពពលកម្ម បង្កលក្ខណៈខាងជីវភាពរស់នៅដល់ជនពិការគ្រប់ប្រភេទ

-សហការជាមួយស្ថាប័នពាក់ព័ន្ធចាត់វិធានការផ្លូវច្បាប់ក្នុងការទប់ស្កាត់អំពើពេស្យាចារ ការជួញដូរមនុស្ស ការរំលោភផ្លូវភេទលើកុមារ ការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍

-សហការជាមួយស្ថាប័នពាក់ព័ន្ធ ជួយដល់ជនរងគ្រោះដោយភយន្តរាយផ្សេងៗ មានគ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀត

-សហការជាមួយស្ថាប័ននិងអង្គការពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិកុមារ

-គ្រប់គ្រងរបបសោធននិវត្តន៍និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់មន្ត្រីរាជការ តាមការកំណត់របស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-គ្រប់គ្រងរបបធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញភារកិច្ច

-គ្រប់គ្រងរបបធានារ៉ាប់រងសង្គម ដល់កូនកំព្រាពីសពមន្ត្រីរាជការ

-ដឹកនាំគ្រប់គ្រង និងសហការជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ដែលធ្វើសកម្មភាពលើវិស័យសង្គមកិច្ច ជាអាទិ៍ ការផ្តល់ព័ត៌មាន ការប្រាប់បង្ហាញ ការណែនាំ និងការផ្តល់សេវាសង្គមកិច្ចនានា

-បំផុសការចូលរួមសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌ សហគមន៍មូលដ្ឋាន ក្នុងការបង្កើតមូលនិធិទ្រទ្រង់ដល់សេវាសង្គមកិច្ចនានា ដើម្បីជួយដល់ជនងាយរងគ្រោះគ្រប់ប្រភេទ។

ខ-វិស័យអតីតយុទ្ធជន

-រៀបចំដាក់ឲ្យដំណើរការ សម្របសម្រួលគោលនយោបាយជាតិស្តីពីអតីតយុទ្ធជន

-រៀបចំបញ្ចូលអតីតយុទ្ធជននិងគ្រួសារទៅក្នុងសហគមន៍ ដោយលើកកម្ពស់ស្ថានភាពរសនៅឲ្យបានល្អប្រសើរនិងគ្មានការរើសអើង តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ការដោះស្រាយការងារធ្វើ និងបង្កើតមុខរបរ

-លើកគោលការណ៍អប់រំណែនាំអតីតយុទ្ធជន ឲ្យយល់ពីតម្លៃកាតព្វកិច្ច តួនាទីក្នុងគ្រួសារ សហគមន៍ និងសង្គមដើម្បីទទួលបានការអភិវឌ្ឍ

-គ្រប់គ្រងរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារសម្រាប់យោធិន នៃកងយោធពលខេមរភូមិន្ទ តាមការកំណត់របស់ច្បាប់ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

-គ្រប់គ្រងនិងដោះស្រាយគោលនយោបាយជូនជនពលីមរណៈ បង្កស្លាប់ បាត់ខ្លួន ពិការ និងគ្រួសារនៃកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជន កងជីវពលដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ។

**គ-វិស័យយុវនីតិសម្បទា**

-គ្រប់គ្រងក្មេងពីអាយុ៧ឆ្នាំ ដល់ក្រោម១៨ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើស ពាលអនាថា អបាយមុខ ក្នុងទូទាំងប្រទេស និងមានតួនាទីកែប្រែ អប់រំ ដើម្បីឲ្យក្លាយទៅជាពលរដ្ឋល្អ

-បង្កើតមណ្ឌលទទួលអប់រំកុមារ តាមការចាំបាច់ដើម្បីទទួលយកកុមារដែលបានប្រព្រឹត្តអំពើខុសឆ្គងមកគ្រប់គ្រង អប់រំ និងបណ្តុះបណ្តាល

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ បង្កើតកម្មវិធីអប់រំ បណ្តុះបណ្តាលអនីតិជន

-សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតតាមពន្ធនាគារ

-កសាងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងវិស័យយុវនីតិសម្បទា

-បង្កើតនិងគ្រប់គ្រងមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងសមាហរណកម្មជនរងគ្រោះទាំងនោះទៅក្នុងសហគមន៍។

**មាត្រា ៤.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរចនាសម្ព័ន្ធ ដូចតទៅ ៖

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានបច្ចេកទេស
- អង្គភាពមូលដ្ឋាន
- គ្រឹះស្ថានសាធារណៈ។

អង្គការលេខរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី ៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៥.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិ ក្នុងជំពូក៦ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី ៤
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា ៦.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

## ជំពូកទី ៥
## អគ្គាធិការដ្ឋាន

**មាត្រា ៧.-**

អគ្គាធិការដ្ឋាន របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទីធ្វើជាសេនាធិការជូនក្រសួងលើការងារ ៖

-ធ្វើអធិការកិច្ចជាប្រចាំ លើគ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ពិនិត្យ សម្រុះសម្រួល និងដោះស្រាយវិវាទរដ្ឋបាល ដែលពាក់ព័ន្ធដល់សមត្ថកិច្ចនិងសកម្មភាពរបស់មន្ត្រី និងភ្នាក់ងាររបស់ក្រសួង

-ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចនិងវិធានការកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រសួងប្រគល់ជូន។

អគ្គាធិការដ្ឋាន ដឹកនាំដោយអគ្គាធិការមួយរូប និងមានអគ្គាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់។

## ជំពូកទី ៦
## អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ

**មាត្រា ៨.-**

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ មានតួនាទីធ្វើជាសេនាធិការរបស់ក្រសួងលើការងារ ៖

-សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួង នៅថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ ដែលពាក់ព័ន្ធទៅនឹងថវិកា ហិរញ្ញវត្ថុ គណនេយ្យ រដ្ឋបាល និងបុគ្គលិក

-រៀបចំផែនការហិរញ្ញវត្ថុរបស់ក្រសួង

-វាយតម្លៃ ជួយសម្រួល ដំឡើងឋានៈ ឬលើកទឹកចិត្តដល់អង្គភាព ឬបុគ្គលដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង

-ត្រួតពិនិត្យវិន័យទូទៅ ចំពោះបុគ្គលិករបស់ក្រសួងនិងអង្គភាពក្រោមឱវាទ

-គ្រប់គ្រងគោលនយោបាយអភិវឌ្ឍធនធានមនុស្សរបស់ក្រសួង

-ទំនាក់ទំនងសាធារណៈនិងការផ្សព្វផ្សាយព័ត៌មាននានារបស់ក្រសួងនៅក្នុងប្រទេស និងក្រៅប្រទេស។

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ រួមមាននាយកដ្ឋាន ៖**

**-នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក**

**-នាយកដ្ឋានផែនការ ស្ថិតិ និងសរុប**

**-នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់**

**-នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ។**

**មាត្រា ៩.-**

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងាររដ្ឋបាលនិងបុគ្គលិកជូនក្រសួង

ក-ផ្នែករដ្ឋបាល

-សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាលនិងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន ដោយសហការជាមួយនាយកដ្ឋានដទៃទៀតក្រោមឱវាទរបស់ក្រសួង

-គ្រប់គ្រងនិងចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់ក្រសួង

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង។

ខ-ផ្នែកបុគ្គលិក

-គ្រប់គ្រងផ្នែករដ្ឋបាលចំពោះមន្ត្រីរាជការនិងភ្នាក់ងាររាជការរបស់ក្រសួង ដោយទាក់ទងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រៀបចំរាល់លិខិតរដ្ឋបាលពាក់ព័ន្ធបុគ្គលិករបស់ក្រសួង សម្រាប់ការគ្រប់គ្រងអាជីព

-ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង

-វាយតម្លៃតម្រូវការ រៀបចំគោលនយោបាយនិងកម្មវិធីបណ្តុះបណ្តាលវិក្រឹតការមន្ត្រីរាជការ និងបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ

-វាយតម្លៃជួយសម្រួលដំឡើងឋានៈ ឬលើកទឹកចិត្តដល់អង្គភាពឬបុគ្គលដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង

-រៀបចំការងារបៀវត្សពលកម្ម ប្រាក់កម្រៃ និងរបបឧបត្ថម្ភគោលនយោបាយសង្គម

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១០.-**

នាយកដ្ឋានផែនការ ស្ថិតិ និងសរុប មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារផែនការ ស្ថិតិ និងសរុបជូនក្រសួង

**ក-ផ្នែកផែនការនិងស្ថិតិ**

-រៀបចំស្ថិតិរបស់មុខសញ្ញាដែលក្រសួងទទួលបន្ទុក

-សិក្សា រៀបចំទិន្នន័យ កំណត់កម្មវិធីសកម្មភាព និងធ្វើគម្រោងផែនការសកម្មភាពការងាររបស់ក្រសួង

-សហការជាមួយនាយកដ្ឋាននានារៀបចំសេចក្តីណែនាំ សារាចរ លិខិតបទដ្ឋាននានា និងផែនការអភិវឌ្ឍរបស់ក្រសួង

-សហការរាល់ការងារបណ្តុះបណ្តាលនិងការអភិវឌ្ឍមុខជំនាញ

-សិក្សាស្ថិតិ និងសិក្សាទិសដៅអនាគត ស្តីពីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានិងបណ្ណាល័យរបស់ក្រសួង។

ខ-ផ្នែកសរុប

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ពិនិត្យ វាយតម្លៃបរិមាណ គុណភាពរបស់រដ្ឋបាល និងសមិទ្ធផលសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ណែនាំរបៀបរបបនិងគ្រប់គ្រងរបបរាយការណ៍ របស់អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត

-ចុះតាមរាជធានី ខេត្តដើម្បីក្តាប់និងប្រមូលសភាពការណ៍ជាក់ស្តែងពីមុខសញ្ញា ដែលក្រសួងទទួលខុសត្រូវ

-ធ្វើរបាយការណ៍ការងារនិងកំណត់ហេតុផ្សេងៗ របស់ថ្នាក់ដឹកនាំក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានផែនការ ស្ថិតិ និងសរុប ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១១.-**

នាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារហិរញ្ញវត្ថុនិងផ្គត់ផ្គង់ជូនក្រសួង

ក-ផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ

-រៀបចំគម្រោងថវិកាក្រសួងនិងតាមដានរំលឹកពីការប្រតិបត្តិ

-ប្រមូលចំណូលឲ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ បង់ចូលថវិការដ្ឋ

-ប្រមូលផ្តុំនិងសម្របសម្រួលជំពូកថវិកា

-តាមដានរំលឹកគ្រប់គ្រងគណនីពិសេស

-ប្រមូលផ្តុំនិងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង

-គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តលទ្ធកម្មសាធារណៈ

-សហការជាមួយអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងការងារត្រួតពិនិត្យចំណូលចំណាយផ្សេងៗរបស់ក្រសួង។

ខ-ផ្នែកផ្គត់ផ្គង់

-ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសម្ភារៈនិងបរិក្ខាររបស់ក្រសួង

-គ្រប់គ្រង ចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌ

-គ្រប់គ្រងយានដ្ឋាននិងយានយន្តរបស់រដ្ឋដែលប្រគល់ឲ្យក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែកចែកប្រេងឥន្ធនៈនិងគ្រឿងបន្លាស់

-ទទួល និងបែកចែកបរិក្ខារ ជូនដល់បណ្តាអង្គភាពរាជធានី ខេត្តនានា

-កាន់បញ្ជីសលាកបត្រជាប្រចាំនិងគណនេយ្យរូបធាតុ

-រៀបចំប្រព័ន្ធព័ត៌មានវិទ្យានៃសកម្មភាពខាងហិរញ្ញវត្ថុនិងបន្ទុកគណនី

-ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១២.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារសហប្រតិបត្តិការអន្តរជាតិជូនក្រសួង

ក-ធ្វើការទាក់ទងជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ដើម្បីចូលរួមចំណែកអភិវឌ្ឍការងារគ្រប់វិស័យរបស់ក្រសួង

-រៀបចំពិធីការសម្រាប់ថ្នាក់ដឹកនាំក្រសួងក្នុងការទទួលភ្ញៀវបរទេស កិច្ចប្រជុំនានា និងពិធីផ្សេងៗរបស់ក្រសួង

-រៀបចំអនុស្សរណៈរវាងក្រសួងជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អង្គការអន្តរជាតិ តាមដានលទ្ធផលនៃការងារអនុវត្ត រាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ

-គ្រប់គ្រង និងតាមដានសកម្មភាពបណ្តាអង្គការនានា តាមកម្មវិធីអនុស្សរណៈ ជួយសម្រួលបែបបទផ្សេងៗរបស់អង្គការនានា ដែលសហការជាមួយក្រសួង។

ខ-គ្រប់គ្រងការងារទាក់ទងសហប្រតិបត្តិការអន្តរជាតិ ដែលពាក់ព័ន្ធជាមួយវិស័យទាំងអស់របស់ក្រសួង

-អនុវត្តការងារសហប្រតិបត្តិការរបស់ក្រសួងក្នុងសហប្រតិបត្តិការអាស៊ាននិងអង្គការអន្តរជាតិផ្សេងៗទៀត ដោយមានកិច្ចសហការជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិអន្តរជាតិ

-សម្រួលលិខិតស្នាម ដូចជាលិខិតឆ្លងដែន ទិដ្ឋាការ របស់មន្ត្រីរាជការក្រោមឱវាទក្រសួង ដែលត្រូវបំពេញបេសកកម្មក្រៅប្រទេស តាមការចាត់តាំងរបស់ក្រសួង

-សរុបសភាពការណ៍អន្តរជាតិ បទពិសោធរបស់បណ្តាប្រទេសក្នុងតំបន់និងសកលលោក ហើយធ្វើការផ្សព្វផ្សាយ ជូនព័ត៌មាននេះដល់អង្គភាពដែលមានការពាក់ព័ន្ធ

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៧
## អគ្គនាយកដ្ឋានបច្ចេកទេស

**មាត្រា ១៣.-**

អគ្គនាយកដ្ឋានបច្ចេកទេស មានតួនាទីធ្វើជាសេនាធិការឲ្យក្រសួងលើការអនុវត្តប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយចំពោះប្រជាជនទូទៅ និងធ្វើការសម្របសម្រួលគ្រប់គ្រងជំនាញកិច្ចការសុខុមាលភាពសង្គម សុខុមាលភាពកុមារ សុខុមាលភាពជនពិការ យុវនីតិសម្បទា សុខុមាលភាពមនុស្សចាស់ អតីតយុទ្ធជន និងប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ។

អគ្គនាយកដ្ឋានបច្ចេកទេស ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

អគ្គនាយកដ្ឋានបច្ចេកទេស រួមមាននាយកដ្ឋាន ៖

-នាយកដ្ឋានសុខុមាលភាពសង្គម

-នាយកដ្ឋានសុខុមាលភាពកុមារ

-នាយកដ្ឋានសុខុមាលភាពជនពិការ

-នាយកដ្ឋានយុវនីតិសម្បទា

-នាយកដ្ឋានសុខុមាលភាពមនុស្សចាស់

-នាយកដ្ឋានអតីតយុទ្ធជន

-នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ។

**មាត្រា ១៤.-**

នាយកដ្ឋានសុខុមាលភាពសង្គម មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារសុខុមាលភាពសង្គមជូនក្រសួង

-កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធការងារសុខុមាលភាពសង្គម

-រៀបចំផែនការសកម្មភាព និងកម្មវិធីជួយសង្គ្រោះដល់ក្រុមជនក្រីក្រងាយរងគ្រោះ និងជួបការលំបាកជាងគេបំផុតនៅក្នុងសង្គម ដើម្បីទប់ស្កាត់ទុគ៌តភាព និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន

-ជំរុញការរៀបចំផែនការសកម្មភាព និងកម្មវិធីជួយជនអនាថា ជនដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងមេរោគឆ្លងកាចសាហាវផ្សេងៗទៀត

-រៀបចំលិខិតបទដ្ឋានសម្រាប់ជួយឧបត្ថម្ភដល់ជនរងគ្រោះដោយមហន្តរាយផ្សេងៗ មានគ្រោះថ្នាក់ធម្មជាតិ សង្គ្រាម និងគ្រោះថ្នាក់ផ្សេងៗទៀត

-បង្កើតមជ្ឈមណ្ឌលសង្គមកិច្ចសម្រាប់ទទួលស្នាក់នៅបណ្តោះអាសន្នស្តារនីតិសម្បទា ថែទាំបណ្តុះ-បណ្តាល និងសមាហរណកម្មជនងាយរងគ្រោះ

-រៀបចំលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ កំណត់អត្តសញ្ញាណជនក្រីក្រដែលត្រូវទទួលសម្បទានដីសង្គមកិច្ច

-រៀបចំផែនការសកម្មភាព កម្មវិធីអភិវឌ្ឍគ្រួសារ និងយេនឌ័រ

-រៀបចំប្រារព្ធទិវាជាតិ និងអន្តរជាតិស្តីពីគ្រួសារ ១៥ឧសភា ជារៀងរាល់ឆ្នាំ

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានសុខុមាលភាពសង្គម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយក-ដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៥.-**

នាយកដ្ឋានសុខុមាលភាពកុមារ មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារសុខុមាលភាពកុមារជូនក្រសួង

-កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងសុខុមាលភាពកុមារ

-អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិកុមារដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី

-គ្រប់គ្រងការផ្តល់សេវាថែទាំ ការពារដល់កុមារកំព្រា ទារកកំព្រាដែលត្រូវគេបោះបង់ចោល

-រៀបចំផែនការសកម្មភាព និងកម្មវិធីផ្តល់សេវាដល់កុមារដែលត្រូវការកិច្ចការពារពិសេស នៅតាមសហគមន៍ និងគ្រួសារ

-រៀបចំនិងអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

-ធ្វើអធិការកិច្ចលើការអនុវត្តបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារតាមមណ្ឌលរដ្ឋ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល

-រៀបចំនិងគ្រប់គ្រងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ

-រៀបចំប្រារព្ធទិវាកុមារអន្តរជាតិ១មិថុនា ជារៀងរាល់ឆ្នាំ

-ជំរុញការអនុវត្តច្បាប់ស្តីពីសុំកូនអន្តរប្រទេស

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានសុខុមាលភាពកុមារ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៦.-**

**នាយកដ្ឋានសុខុមាលភាពជនពិការ មានភារកិច្ចដូចតទៅ ៖**

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារសុខុមាលភាពជនពិការជូនក្រសួង

-កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងសុខុមាលភាពជនពិការ

-ជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

-អនុវត្តអនុសញ្ញាអន្តរជាតិនានាពាក់ព័ន្ធនឹងសិទ្ធិជនពិការ

-ធ្វើអធិការកិច្ចលើការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

-រៀបចំផែនការសកម្មភាពសម្រាប់អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ

-រៀបចំផែនការសកម្មភាពសម្រាប់ការងារស្តារលទ្ធភាពពលកម្មជនពិការ

-រៀបចំផែនការសកម្មភាពដោះស្រាយមុខរបរនិងការងារជូនជនពិការ

-រៀបចំផែនការសកម្មភាពផលិតនិងផ្តល់ឧបករណ៍អវយវៈសិប្បនិម្មិតរណប និងឧបករណ៍ជំនួយការដើរផ្សេងៗសម្រាប់ជនពិការ

-រៀបចំផែនការសកម្មភាពវប្បធម៌ សិល្បៈ និងកីឡាជនពិការ

-រៀបចំ ប្រារព្ធទិវាជនពិការអន្តរជាតិ ៣ធ្នូ និងទិវាជនពិការផ្សេងទៀត ជារៀងរាល់ឆ្នាំ

-រៀបចំផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍសេវាអក្សរស្ទាបនិងភាសាសញ្ញា

-រៀបចំនិងដំណើរការមូលនិធិជនពិការ

-រៀបចំផែនការសកម្មភាព និងដំណើរការការងារស្តារលទ្ធភាពពលកម្មនៅសហគមន៍

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានសុខុមាលភាពជនពិការ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៧.-**

នាយកដ្ឋានយុវនីតិសម្បទា មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារយុវនីតិសម្បទាជូនក្រសួង

-កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងយុវនីតិសម្បទា

-ជំរុញការរៀបចំនិងការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន

-រៀបចំផែនការសកម្មភាព និងកម្មវិធីអប់រំដើម្បីទប់ស្កាត់អំពើល្មើសច្បាប់ និងការប្រើប្រាស់បំពានគ្រឿងញៀនខុសច្បាប់ក្នុងមជ្ឈដ្ឋានកុមារ

-រៀបចំផែនការសកម្មភាពសម្រាប់ការពារសិទ្ធិកុមារតាមផ្លូវច្បាប់ដែលនៅតាមពន្ធនាគារ

-រៀបចំផែនការសកម្មភាពបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ទណ្ឌិតនៅតាមពន្ធនាគារ

-សហការរៀបចំផែនការសកម្មភាព ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមសហគមន៍ និងគ្រួសារ

-រៀបចំមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលអនីតិជនប្រព្រឹត្តល្មើសនឹងច្បាប់ និងធ្វើសមាហរណកម្មទៅសហគមន៍វិញ

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានយុវនីតិសម្បទា ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៨.-**

នាយកដ្ឋានសុខុមាលភាពមនុស្សចាស់ មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារសុខុមាលភាពមនុស្សចាស់ជូនក្រសួង

-កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងសុខុមាលភាពមនុស្សចាស់

-អនុវត្តអនុសញ្ញាអន្តរជាតិនានាពាក់ព័ន្ធនឹងមនុស្សចាស់

-រៀបចំផែនការសកម្មភាពផ្តល់សេវាថែទាំមនុស្សចាស់ជរាក្រីក្រគ្មានទីពឹង

-រៀបចំផែនការសកម្មភាពនិងកម្មវិធីអភិវឌ្ឍសមាគមមនុស្សចាស់

-រៀបចំផែនការសកម្មភាពនិងកម្មវិធីអភិវឌ្ឍសមាគមអតីតមន្ត្រីរាជការស៊ីវិល

-រៀបចំផែនការសកម្មភាពនិងកម្មវិធីបង្កើតមជ្ឈមណ្ឌលមនុស្សចាស់ជរា

-រៀបចំផែនការសកម្មភាពនិងកម្មវិធីផ្តល់សេវាថែទាំមនុស្សចាស់ជរា

-រៀបចំផែនការសកម្មភាពនិងកម្មវិធីផ្តល់សេវាសុខុមាលភាពមនុស្សចាស់នៅតាមសហគមន៍ និងវត្តអារាម

-រៀបចំទិវាមនុស្សចាស់អន្តរជាតិ ១ តុលា ជារៀងរាល់ឆ្នាំ និងទិវាផ្សេងៗពាក់ព័ន្ធមនុស្សចាស់

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានសុខុមាលភាពមនុស្សចាស់ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ១៩.-**

**នាយកដ្ឋានអតីតយុទ្ធជន** មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារអតីតយុទ្ធជនជូនក្រសួង

-កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងអតីតយុទ្ធជន

-អនុវត្តអនុសញ្ញាអន្តរជាតិនានាពាក់ព័ន្ធនឹងអតីតយុទ្ធជន

-រៀបចំផែនការសកម្មភាពនិងកម្មវិធីអភិវឌ្ឍ ចលនាបង្កើតស្នាដៃល្អក្នុងជួរអតីតយុទ្ធជន

-រៀបចំផែនការសកម្មភាព និងកម្មវិធីអភិវឌ្ឍសមាគមអតីតយុទ្ធជនកម្ពុជា

-ធ្វើការទាក់ទង សម្របសម្រួលជាមួយស្ថាប័ននិងអាជ្ញាធរដែនដី ដើម្បីទាក់ទាញការជួយឧបត្ថម្ភគាំទ្រចំពោះអតីតយុទ្ធជន

-រៀបចំប្រារព្ធទិវាអតីតយុទ្ធជន ថ្ងៃ២១ មិថុនា ជារៀងរាល់ឆ្នាំ និងទិវាផ្សេងៗទាក់ទងនឹងអតីតយុទ្ធជន

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានអតីតយុទ្ធជន ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ២០.-**

**នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ** មានភារកិច្ចដូចតទៅ ៖

-គ្រប់គ្រង ដឹកនាំ និងចាត់ចែងការងារប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះជូនក្រសួង

-កសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ

-អនុវត្តអនុសញ្ញាអន្តរជាតិនិងកិច្ចព្រមព្រៀងអន្តរជាតិនានាពាក់ព័ន្ធនឹងការប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ

-រៀបចំផែនការសកម្មភាពនិងកម្មវិធីអនុវត្តសកម្មភាពដែលពាក់ព័ន្ធការងារប្រឆាំងនឹងការជួញដូរមនុស្ស

-រៀបចំផែនការសកម្មភាពនិងកម្មវិធីស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅសហគមន៍វិញ

-អនុវត្តគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស

-រៀបចំផែនការសកម្មភាព និងកម្មវិធីដំណើរការប្រព័ន្ធកំណាត់អត្តសញ្ញាណ ការពារ ស្វែងរកគ្រួសារ បានប្រមាណគ្រួសារ ធ្វើសមាហរណកម្ម និងឧបត្ថម្ភគាំទ្រដល់ជនរងគ្រោះនិងជនងាយរងគ្រោះដោយសារការជួញដូរមនុស្សក្នុងប្រទេសនិងឆ្លងកាត់ព្រំដែន ជនរងគ្រោះដោយសារការកេងប្រវញ្ច ឬទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន និងជនរងគ្រោះដែលត្រូវបានធ្វើសមាហរណកម្មពីមជ្ឈមណ្ឌលសង្គ្រោះនានា ទៅសហគមន៍វិញ

-ធ្វើអធិការកិច្ចការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមមជ្ឈមណ្ឌលរដ្ឋនិងអង្គការមិនមែនរដ្ឋាភិបាល

-រៀបចំផែនការសកម្មភាព និងកម្មវិធីគ្រប់គ្រងជនងាយរងគ្រោះដោយសារអំពើជួញដូរមនុស្ស

-រៀបចំមជ្ឈមណ្ឌលស្តារនីតិសម្បទា និងបណ្តុះបណ្តាលជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ

-រៀបចំមជ្ឈមណ្ឌលស្តារនីតិសម្បទានិងបណ្តុះបណ្តាលជនរងគ្រោះដោយអំពើជួញដូរមនុស្សផ្សេងៗ

-រៀបចំនិងដំណើរការមជ្ឈមណ្ឌលសំចត សម្រាប់ជនរងគ្រោះ មាតុភូមិនិវត្តន៍ពីប្រទេសនានា និងធ្វើសមាហរណកម្ម

-ធ្វើរបាយការណ៍សរុបពីសកម្មភាពនិងលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ប្រាំបួនខែ និងប្រចាំឆ្នាំជូនក្រសួង

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការតាមការចាំបាច់។

## ជំពូកទី ៨
## អង្គភាពមូលដ្ឋាន

**មាត្រា ២១.-**

នៅតាមរាជធានី ខេត្ត នីមួយៗ មានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពរបស់ក្រសួង។

នៅតាមក្រុង ស្រុក ខណ្ឌ មានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលទទួលបន្ទុកអនុវត្តនិងសម្របសម្រួលសកម្មភាពរបស់ក្រសួងនិងតាមបទបញ្ជារបស់មន្ទីរ។

## ជំពូកទី ៩
## គ្រឹះស្ថានសាធារណៈ

**មាត្រា ២២.-**

គ្រឹះស្ថានសាធារណៈដែលស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមមាន ៖

-បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-បេឡាជាតិអតីតយុទ្ធជន

-មូលនិធិជនពិការ

គ្រឹះស្ថានសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

## ជំពូកទី ១០
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២៣.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង។

## ជំពូកទី ១១
## អន្តរប្បញ្ញត្តិ

**មាត្រា ២៤.-**

អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន និងអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ នៅមានអនុភាពគតិយុត្តបន្តទៅមុខទៀត។

**មាត្រា ២៥.-**

មន្ត្រីរាជការដែលបម្រើការនៅក្នុងរចនាសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្ទេរទៅក្នុងរចនាសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី ១២
## អវសានប្បញ្ញត្តិ

**មាត្រា ២៦.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ២៧.-**

ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងប្រធានស្ថាប័ននៃស្ថាប័នដទៃទាំងនោះ ត្រូវសហការគ្នាដើម្បីបែងចែកការទទួលខុសត្រូវនិងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងប្រធានស្ថាប័នទាំងនោះ។

**មាត្រា ២៨.-**

អនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ទី៣ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីសូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**អ៊ិត សំហេង**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៤ . អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១
## អង្គការលេខក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**រដ្ឋមន្ត្រី**

- រដ្ឋលេខាធិការ
- អនុរដ្ឋលេខាធិការ
- ខុទ្ទកាល័យ-ទីប្រឹក្សា

**អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ**

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានផែនការ ស្ថិតិ និងសរុប
- នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

**អគ្គនាយកដ្ឋានបច្ចេកទេស**

- នាយកដ្ឋានសុខុមាលភាពសង្គម
- នាយកដ្ឋានសុខុមាលភាពកុមារ
- នាយកដ្ឋានសុខុមាលភាពជនពិការ
- នាយកដ្ឋានយុវនីតិសម្បទា
- នាយកដ្ឋានសុខុមាលភាពមនុស្សចាស់
- នាយកដ្ឋានអតីតយុទ្ធជន
- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ

**អគ្គាធិការដ្ឋាន**

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង

គ្រឹះស្ថានសាធារណៈ

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត

- ការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ១០.០០០ ហិកតា
## ស្ថិតនៅក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១០.០០០ ( មួយម៉ឺន) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគីរី ដើម្បីវិនិយោគដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ ២៥២ អនព ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ របស់សាលាខេត្តមណ្ឌលគីរី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថាន ប៉េ អេស អឺ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រម នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១ :** ត្រូវបានទទួលស្គាល់វិទ្យាស្ថាន ប៉េ អេស អឺ ដែលមានអក្សរកាត់ “វ.ប.អ.អ.” និងជាអក្សរឡាតាំងថា “Institut PSE” ដែលមានអក្សរកាត់ “I.P.S.E”។ វិទ្យាស្ថាន ប៉េ អេស អឺ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**មាត្រា ២ :** វិទ្យាស្ថាន ប៉េ អេស អ៊ី មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- ថ្នាក់វិញ្ញាបនបត្រ សិក្សារយៈពេលខ្លីក្រោម ១ ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សិក្សារយៈពេល ១ឆ្នាំ ២ឆ្នាំ ៣ឆ្នាំ
- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ ត្រូវនឹង ៨០ ក្រេឌីត
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ១៦០ ក្រេឌីត។

**មាត្រា ៣ :** ចំពោះមុខវិទ្យាស្ថាន ប៉េ អេស អ៊ី មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យទំនាក់ទំនងសាធារណៈ
- ការិយាល័យស្រាវជ្រាវ
- ការិយាល័យបង្កើតមុខរបរ
- ការិយាល័យធានាគុណភាពសិក្សា និងកម្មវិធីសិក្សា
- ដេប៉ាតឺម៉ង់សណ្ឋាគារ និងទេសចរណ៍
- ដេប៉ាតឺម៉ង់ពាណិជ្ជសាស្ត្រ
- ដេប៉ាតឺម៉ង់វិស្វកម្មយានយន្ត

នៅថ្ងៃអនាគតវិទ្យាស្ថាននេះអាចបើកសាខា ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៤ :** លក្ខខណ្ឌទទួលសិស្ស និស្សិតឲ្យចូលរៀន ៖

- ថ្នាក់វិញ្ញាបនបត្រ សម្រាប់បេក្ខជនជាសិក្ខាកាម សិស្ស និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់បេក្ខជនបានរៀនចប់ថ្នាក់ទី ៩ នៃមធ្យមសិក្សាបឋមភូមិ ឬវិញ្ញាបនបត្រកម្មវិធីស្ពានចម្លងបន្តជំនាញ
- ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សម្រាប់បេក្ខជនមានសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត ៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សម្រាប់បេក្ខជនមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើស ការបណ្តុះបណ្តាល ការប្រឡងបញ្ចប់ការសិក្សារបស់សិស្ស-និស្សិត។

**មាត្រា ៥ :** វិទ្យាស្ថាន ប៉េ អេស អ៊ី មាននាយកមួយរូប និងមាននាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេលមួយត្រីមាសម្តង ឲ្យបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៦ :** សិស្ស និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងតាមឯកទេស

ដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឲ្យដោយវិទ្យាស្ថាន ប៉េ អេស អ៊ី នឹងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៧ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថាន ប៉េ អេស អ៊ី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិបណ្តុះបណ្តាល*
- *គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា*
- *គ្រប់ខេត្ត-រាជធានី*
- *ដូចមាត្រា ៨*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជនចំនួន ១៦ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ និងហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ ស្ថិតនៅក្នុងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ដែលមានរាយនាមខាងក្រោម ៖

**ក. មេដាយមាសស្ថាបនាជាតិចំនួន ០៤ គ្រឿង ផ្តល់ជូន ៖**

១-លោក **ជៀម ផេន** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៧.០០០ ដុល្លារ

២-លោក **ហួរ ហាប់** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៥.០០០ ដុល្លារ

៣-លោក **ឃួន សារិន** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១៥.០០០ ដុល្លារ

៤-លោក **មីន រស្មី** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១៥.០០០ ដុល្លារ

**ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០១ គ្រឿង ផ្តល់ជូន**

លោក **នី ដេង** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ៦.៥០០ ដុល្លារ

**គ. មេដាយសំរិទ្ធស្ថាបនាជាតិចំនួន ១១ គ្រឿង ផ្តល់ជូន ៖**

១-លោក **ប៊ុន អ៊ើ** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ៤.៩១៦ ដុល្លារ

២-លោកស្រី **ញាំ មឿន** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ២.៩០០ ដុល្លារ

៣-លោក **នុត សារ៉ា** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ២.០០០ ដុល្លារ

៤-លោក **សុខ ខៀន** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១.៩៨៦ ដុល្លារ

៥-លោក **ថន ឃីន** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១.៦០០ ដុល្លារ

៦-លោក **ផាត់ ស៊ុន** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១.២០០ ដុល្លារ

៧-លោកស្រី **សារ៉ា សុខាសាន្ត** សប្បុរសជនរស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១.០០០ ដុល្លារ

៨-លោក **ឆៅ ម៉ឹច** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១.០០០ ដុល្លារ

៩-លោក **ម៉ា ធី** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១.០០០ ដុល្លារ

១០-លោក **ចំប៉ា ត្នូចប៊ុនឈូ** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១.០០០ ដុល្លារ

១១-លោក **ខ្ញធិត ចាន់យ៉ា** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ១.០០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកោះកុង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជនចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យ ព្រះពុទ្ធសាសនា អប់រំ និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ស្ថិតនៅក្នុងឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ដែលមានរាយនាមដូចខាងក្រោម ៖

**ក- មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទចំនួន ០១ គ្រឿង ផ្តល់ជូន**

លោកស្រី **យន្ត ឈុនហួរ** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ៥០.០០០ ដុល្លារ

**ខ- មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនាចំនួន ០១ គ្រឿង ផ្តល់ជូន**

លោក **មីន មករា** សប្បុរសជននៅខេត្តកោះកុង ថវិកាចំនួន ៤៦.០០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកោះកុង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣០៣...អនក្រ.ទស

# អនុក្រឹត្យ
# ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនថ្នាក់ដឹកនាំអង្គការក្រៅរដ្ឋាភិបាល ចំនួន០៤រូប ដែលបានខិតខំប្រឹងប្រែងយកអស់កំលាំងកាយចិត្ត ដើម្បីរកមូលនិធិ ជួយសាងសង់ផ្ទះជូនប្រជាពលរដ្ឋក្រីក្រ នៅភូមិអណ្តូង សង្កាត់គោករការ ខណ្ឌដង្កោ រាជធានីភ្នំពេញ ក្នុងនោះអង្គភាព Care The Poor ផ្តល់ថវិកាចំនួន ៦៤.000 ដុល្លារ រួមជាមួយថវិកាបដិភាគរបស់មូលនិធិ UPDF សាងសង់ផ្ទះរួចរាល់ជាស្ថាពរ ចំនួន១០០ខ្នង និង អង្គការ People for Care & learning សាងសង់ផ្ទះចំនួន៥០ខ្នង ចំណាយអស់ថវិកាចំនួន ៥០.000 ដុល្លារ និងកំពង់សាងសង់ ៥០ខ្នងទៀត ព្រមទាំងជួយសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសហគមន៍ភូមិអណ្តូងនេះបន្ថែមទៀត ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក | Dr. Fred Garmon | នាយកអង្គការ People for Care & learning |
| ២-លោក | Benjamin Komanapalli | នាយកអង្គការ Care the Poor |
| ៣-លោក | Dr. John Gregary | ប្រធានមូលនិធិអង្គការ People for Care & learning |
| ៤-លោក | Dr. Bien Raneses | ប្រធានអភិវឌ្ឍន៍អង្គការ People for Care & learning |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១១
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣០៥.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦១០ /៤៦៤ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ចំនួន០៦រូប នៃក្រសួងមហាផ្ទៃ ដែលកំពុងបំរើការងារនៅអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដូចមានរាយនាមខាងក្រោមៈ

១-លោកវរសេនីយ៍ទោ **ឃី សិទ្ធិ** អត្តលេខ ០៥១០៨

២-លោកវរសេនីយ៍ទោ **ហេង ច័ន្ទដារ៉ា** អត្តលេខ ០៨៣២៨

៣-លោកវរសេនីយ៍ទោ **ជ័យ ជាតិ** អត្តលេខ ១២៦៦១

៤-លោកវរសេនីយ៍ទោ **ម៉ែន ដារី** អត្តលេខ ១២៩៩២

៥-លោកវរសេនីយ៍ទោ **ឈុក ស្រគុំ** អត្តលេខ ៣២៣២៧

៦-លោកវរសេនីយ៍ទោ **លឹម ឆាង** អត្តលេខ ៣២៣៦៣

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មិនា ឆ្នាំ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួលៈ*

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាលកម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣០៩ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការតែងតាំង និង ផ្ទេរភារកិច្ចមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**សម្រេច**

**មាត្រា ១:** តែងតាំងមន្ត្រីរាជការ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន ០៥ រូប ដូចមានរាយនាមខាងក្រោមៈ

១. លោក **ទឹង សុមិត្ត** ជាអនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ថ្នាក់ស្មើ អគ្គនាយករង

២. លោក **គីម ចន្ទតារា** ជាអនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ថ្នាក់ស្មើ អគ្គនាយករង

៣. លោក **ម៉េង សេរីវ៉ាត់** ជាប្រធាននាយកដ្ឋានមន្ទីរពិសោធន៍មាត្រាសាស្ត្រ

៤. លោកស្រី **ស៊ិន សុមុលីន** ជាប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ

៥. លោក **អ៊ុំ ពៅពិសី** ជាប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ

**មាត្រា ២:** ផ្ទេរភារកិច្ចលោក **ទី ប៉ូលីននារិទ្ធ** ពីអធិការនៃអគ្គាធិការដ្ឋាន ឲ្យមកជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍ និងសហប្រតិបត្តិការមាត្រាសាស្ត្រ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ០៣ ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយប្រាក់ការងារ** ជូនអស់លោក លោកស្រីមន្ត្រីរាជការស៊ីវិលនៅសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យចំនួន ២៤ រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

| | | |
|---|---|---|
| ១-លោក | **ជុំ ឈុននី** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ២-លោក | **ញ៉ៀម អេន** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ៣-លោក | **អោម សារ៉ាត** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ៤-លោក | **ឆាញ សំអុន** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ៥-លោក | **ទូច ពា** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ៦-លោក | **សេង សំបឿន** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ៧-លោកស្រី | **អ៊ុក ម៉ាឡៃ** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ៨-លោកស្រី | **ជឹម ធី** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ៩-លោក | **យ៉ែម សាមុត** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១០-លោក | **ឃុន លី** | សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១១-លោក | **តេង សុគុន** | នាយករងរដ្ឋបាលសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |

| | | |
|---|---|---|
| ១២-លោក | អ៊ុំ សៀកលី | អនុប្រធានការិយាល័យសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១៣-លោកស្រី | លីម គីមឈន់ | មន្ត្រីសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១៤-លោក | គង់ វិចិត្រ | មន្ត្រីសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១៥-លោក | ទ្រាក់ ប៊ុនឃិន | ប្រធានការិយាល័យសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១៦-លោក | យឹម សុផល | អនុប្រធានការិយាល័យសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១៧-លោក | នា ចាន់ណារ៉ា | មន្ត្រីសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១៨-លោក | សួន រ៉េន | មន្ត្រីសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ១៩-លោក | ខួន លីន | មន្ត្រីសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ២០-លោក | ជុំ អឿន | មន្ត្រីសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ២១-លោក | ឈៀង សេងលេង | ប្រធានការិយាល័យសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ២២-លោក | ទ្រាប សុផល | អនុប្រធានការិយាល័យសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ២៣-លោក | កែវ យ៉ន | មន្ត្រីសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ២៤-លោក | អ៊ាត សាមីន | មន្ត្រីសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣១១ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនអស់លោក លោកស្រី ជាមន្ត្រីរាជការស៊ីវិលនៅសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យចំនួន ០៩ រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ច ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

ក- **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** :

| | | |
|---|---|---|
| ១-លោក | **យឹម ផាន់ណា** | អភិបាលស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |
| ២-លោក | **ទឹម សារ៉ាត់** | អភិបាលរងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |

ខ- **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** :

| | | |
|---|---|---|
| ១-លោកស្រី | **គង់ ម៉ុំ** | អភិបាលរងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ |

២-លោក **ម៉ែន ចណ្ណះ** អភិបាលរងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

៣-លោក **ពើយ សារឿន** ប្រធានក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

៤-លោក **ជិន សាមច់** សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

៥-លោក **ធាន សៀក** សមាជិកក្រុមប្រឹក្សាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

៦-លោក **ខួន សំអឿន** នាយករដ្ឋបាលសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

៧-លោក **សរ សារ៉េត** ប្រធានការិយាល័យសាលាស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០១១*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនអស់លោក លោកស្រីមន្ត្រីរាជការស៊ីវិលនៅសាលារាជធានីភ្នំពេញចំនួន ១៣៣ រូប ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម :

**ក- មេដាយមាសការងារ**

| | | |
|---|---|---|
| ១-លោក | សាំ ពិសិដ្ឋ | នាយកទីចាត់ការរៀបចំក្រុងសាលារាជធានីភ្នំពេញ |
| ២-លោក | សែស សុខកុសល | នាយករងទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្សសាលារាជធានីភ្នំពេញ |
| ៣-លោក | ជុំ មុរិន | នាយករងទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្សសាលារាជធានីភ្នំពេញ |
| ៤-លោក | សូ សិទ្ធី | ប្រធានការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិសាលារាជធានីភ្នំពេញ |
| ៥-លោក | សួរ ដារ៉ា | ប្រធានការិយាល័យគ្រប់គ្រងការអភិវឌ្ឍ និងសំណង់សាលារាជធានីភ្នំពេញ |
| ៦-លោក | មុត សុវណ្ណ | ប្រធានការិយាល័យកិច្ចការច្បាប់ និងដោះស្រាយវិវាទនៅមូលដ្ឋានសាលារាជធានីភ្នំពេញ |
| ៧-លោក | ថៃ ដារ៉ា | ប្រធានការិយាល័យសេដ្ឋកិច្ច និងសង្គមកិច្ចសាលារាជធានីភ្នំពេញ |
| ៨-លោកស្រី | ម៉ក់ សុគាឌី | អនុប្រធានការិយាល័យរបៀប និងឯកសារសាលារាជធានីភ្នំពេញ |
| ៩-លោកស្រី | អៀង សុវិណ្ណា | អនុប្រធានការិយាល័យសរុប និងព័ត៌មានសាលារាជធានីភ្នំពេញ |
| ១០-លោកស្រី | ចេង ចិន្តា | អនុប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សាសាលារាជធានីភ្នំពេញ |
